កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍
# ស្តីពី
# វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៥
# នៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី
# របស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## (សេចក្តីព្រាង)

ខែធ្នូ ឆ្នាំ២០១៥

# មាតិកា


I. សេចក្តីផ្តើម ........................................................................ ៣

II. លទ្ធផលសម្រេចបាន ................................................................ ៣

III. បញ្ហាប្រឈម ........................................................................ ២២

IV. សំណូមពរ ............................................................................ ២៣

V. សេចក្តីសន្និដ្ឋាន ...................................................................... ២៣

ឧបសម្ព័ន្ធ ÷ របាយការណ៍វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៥ ........................... ពៀរ1 ពៀ្យកមារក ឆៀត ដទើនដេខ

## I. សេចក្តីផ្តើម

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានមកដល់ដំណាក់កាលអន្តរកាលនៃការអនុវត្តបញ្ចប់ដំណាក់កាលទី២ គឺ “គណនេយ្យភាពហិរញ្ញវត្ថុ” នៅក្នុងឆ្នាំ២០១៥នេះ ឆ្ពោះទៅចាប់ផ្តើមការអនុវត្តដំណាក់កាលទី៣ ដែលផ្តោតលើ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ក្នុងឆ្នាំ២០១៦ ខាងមុខ តាមរយៈការអនុវត្តផែនការសកម្មភាពដំណាក់កាលទី២ ថ្មី (CAP 2-New) ដែលត្រូវអនុវត្តសម្រាប់រយៈពេលមួយឆ្នាំ និង ៦ខែ គឺសម្រាប់ឆមាសទី២ ឆ្នាំ២០១៤ និងសម្រាប់មួយឆ្នាំ២០១៥។

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានតាមដាននិងត្រួតពិនិត្យតាមរយៈយន្តការច្បាស់លាស់ គ្រប់គ្រាន់ និងទៀងទាត់ ដែលរួមមានការត្រួតពិនិត្យប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសនេះ គឺជារបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី២ថ្មី (CAP 2-New) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរៀបរាប់ពីលទ្ធផលសម្រេចបានដោយលម្អិតទៅតាមផ្នែកនីមួយៗ រហូតដល់កម្រិតគោលបំណង និងចង្កោមសកម្មភាព ធៀបនឹងសូចនាករ ព្រមទាំងលើកឡើងពីបញ្ហាប្រឈម និងអនុសាសន៍ ព្រមទាំងការងារដែលត្រូវអនុវត្តបន្តផងដែរ។

វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ផ្អែកលើមូលដ្ឋាន ២ គឺ÷

១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត

២. លទ្ធផលសម្រេចបាន ធៀបនឹងសូចនាករគោលដៅ។

ចំណែកឯ ការផ្តល់និទ្ទេសវាយតម្លៃលើវឌ្ឍនភាពសម្រេចបាន ត្រូវបានចែកចេញជា ៤កម្រិត គឺ÷

- ១០០% ÷ ល្អ
- ខ្ពស់ជាង ឬ ស្មើ ៨០% ÷ ល្អបង្គួរ
- ខ្ពស់ជាង ៥០% ÷ មធ្យម
- ទាបជាង ឬ ស្មើ ៥០% ÷ ខ្សោយ។

## II. លទ្ធផលសម្រេចបាន

### ផ្នែកទី១: ភាពជឿទុកចិត្តបាននៃថវិកា

ផ្នែកទី១ ភាពជឿទុកចិត្តបាននៃថវិកា ក្នុង CAP 2 New ត្រូវពង្រឹងតាមរយៈគោលបំណងចំនួន ៤ គឺការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល, ការពង្រឹងការគ្រប់គ្រងបំណុល, ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី និងការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ ដែលគាំទ្រដោយចង្កោមសកម្មភាពចំនួន ១៤។

ជារួម ផ្អែកលើគោលបំណងដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៧៦% ដែលក្នុងនោះ គោលបំណងទី ១១, ទី១២ និងទី ១៤ សម្រេចបានទាបជាង ៨០% ។

## ១. លទ្ធផលលើសូចនាករសមិទ្ធកម្មគន្លឹះ

| សូចនាករ | គោលដៅ | ចន្លោះលទ្ធភាពត្រីមាសទី៣ ឆ្នាំ២០១៤ | ចន្លោះលទ្ធភាពត្រីមាសទី៣ ឆ្នាំ២០១៥ |
|---|---|---|---|
| **១. លទ្ធផលចំណូលក្នុងស្រុកសរុប ជាបណ្តើរៗកាន់តែខិតទៅរកគោលដៅ ដែលបានអនុម័ត នៅក្នុងច្បាប់ហិរញ្ញវត្ថុ** | ចំណូលក្នុងស្រុកសរុបសម្រេចបាន +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ | ចំណូលក្នុងស្រុកសម្រេចបាន÷<br>☐ត្រីមាសទី៣: ៧៦,៧%<br>• ចំណូលចរន្ត : ៧៨,០%<br>• ចំណូលមូលធន : ១៦,៧%<br>ការអនុវត្តផែនការប្រមូលចំណូលធៀបនឹងផែការត្រីមាសទី៣÷<br>- គយ និងរដ្ឋាករ :១១៤,២៦%<br>- ពន្ធដារ : ១១៩,០៥%<br>- ទ្រព្យសម្បត្តិរដ្ឋ : ៨៩,៩៣%<br>- ឧស្សាហកម្មហិរញ្ញវត្ថុ :១២៣,៨៣% | ចំណូលក្នុងស្រុកសម្រេចបាន÷<br>☐ត្រីមាសទី៣: ៧៧,៤%<br>• ចំណូលចរន្ត : ៧៧,៧%<br>• ចំណូលមូលធន : ៥៣,៨%<br>ការអនុវត្តផែនការប្រមូលចំណូលធៀបនឹងផែការត្រីមាសទី៣÷<br>- គយ និងរដ្ឋាករ : ១០២,៥%<br>- ពន្ធដារ : ៩៦,៩%<br>- ទ្រព្យសម្បត្តិរដ្ឋ : ១១៥,៤៦%<br>- ឧស្សាហកម្មហិរញ្ញវត្ថុ: ១១៤,១៧% |
| **២. បំណុលកកស្ទះថ្មី** | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២%នៃចំណាយសរុប | គ្មាន | គ្មាន |
| **៣. បញ្ហាចំណាយទៅតាមកម្មវិធីចំណាយនិងផែនការសាច់ប្រាក់** | ស្ថានភាពចំណាយមិនត្រូវតិចជាង:<br>☐ ត្រីមាសទី១: ១៥%<br>☐ ត្រីមាសទី២: ៤៥%<br>☐ ត្រីមាសទី៣: ៦៧%<br>☐ ត្រីមាសទី៤: ៩៦%<br><br>ភាគរយនៃការទូទាត់ជូនអ្នកផ្គត់ផ្គង់និងបុគ្គលិកតាមប្រព័ន្ធធនាគារមិនត្រូវតិចជាង៨០% នៃចំណាយសរុប<br><br>ភាគរយនៃការបង់ចំណូលតាមរយៈប្រព័ន្ធ ធនាគារមិនត្រូវតិចជាង៦០%នៃចំណាយសរុប | ចំណាយថវិកាជាតិសម្រេចបានក្នុង÷<br>☐ ត្រីមាសទី៣: ៥៦%<br><br>ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>☐ត្រីមាសទី៣: ១០០%<br>▪ ក្រសួងចំនួន ៣៦ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ<br>ត្រីមាសទី៣÷<br>☐ចំណូលពន្ធគយ:<br>• ៩២% បង់តាមធនាគារដោយអតិថិជន<br>• ៨% បង់តាមធនាគារដោយគយ<br>☐ចំណូលពន្ធដារ:<br>• ៨៧,១% បង់តាមធនាគារដោយអ្នកជាប់ពន្ធ<br>• ១២,៩% បង់តាមធនាគារដោយពន្ធដារ | ចំណាយថវិកាជាតិសម្រេចបានក្នុង÷<br>☐ ត្រីមាសទី៣: ៥៧,៤%<br><br>ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>☐ ត្រីមាសទី៣: ១០០%<br>▪ ក្រសួងចំនួន ៣៧ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ<br>ត្រីមាសទី៣÷<br>☐ចំណូលពន្ធគយ:<br>• ៩២,៦% បង់តាមធនាគារដោយអតិថិជន<br>• ៧,៤% បង់តាមធនាគារដោយគយ<br>☐ចំណូលពន្ធដារ:<br>• ៩៨,៩% បង់តាមធនាគារដោយអ្នកជាប់ពន្ធ<br>• ១,១% បង់តាមធនាគារដោយពន្ធដារ |
| **៤. ចំណាយតាមប្រភេទ (សម្រាប់បុគ្គលិក) កាន់តែខិតទៅរកថវិកាដែលបានអនុម័ត** | លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>☐ បៀវត្ស: ៩៨%<br>☐ ទំនិញ/សេវា: ៩៥%<br>☐ មូលធន: ៨៥% | ចំណាយថវិកាជាតិសម្រេចបាន÷<br>ត្រីមាសទី៣÷<br>☐ បៀវត្ស: ៧៤,៥%<br>☐ ទំនិញ/សេវា: ៤៣,៥%<br>☐ មូលធន: ៦២,៤% | ចំណាយថវិកាជាតិសម្រេចបាន:<br>ត្រីមាសទី៣÷<br>☐ បៀវត្ស: ៧២,២%<br>☐ ទំនិញ/សេវា: ៤១,៣%<br>☐ មូលធន: ៤៩,០% |

| សូចនាករ | គោលដៅ | វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៤ | វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៥ |
|---|---|---|---|
| **៥. ទិន្នផលចំណូលលើមូលដ្ឋានពន្ធកាន់តែប្រសើរជាងមុនតាមរយៈការកែលម្អប្រសិទ្ធភាពនៃការប្រមូលនិងផែនការប្រើប្រាស់ប្រភពចំណូលមិនមែនសារពើពន្ធ** | ការរួមចំណែកទៅក្នុង ផ.ស.ស. នៃចំណូលសរុបមានការកែលម្អដោយបង្កើនប្រមាណ ០.៥% ក្នុងមួយឆ្នាំ | □ចំណូលសារពើពន្ធ÷៨០,៣%<br>• ពន្ធផ្ទាល់: ៨៨,១%<br>• ពន្ធប្រយោល : ៧៥២%,<br>ចំណូលមិនមែនសារពើពន្ធ : ៦៥,១% | □ចំណូលសារពើពន្ធ÷៨០,៩%<br>• ពន្ធផ្ទាល់ : ៩៥,៩%<br>• ពន្ធប្រយោល: ៧៦,២%<br>ចំណូលមិនមែនសារពើពន្ធ : ៥៧,១% |
| **៦. រាល់ផ្នែកសំខាន់ៗនៃចំណូល និងចំណាយសាធារណៈត្រូវបានដាក់បញ្ចូលក្នុងថវិកានិងគណនីរបស់ រដ្ឋាភិបាល** | មិនមានផ្នែកសំខាន់ៗដែលត្រូវបានដកចេញ | ចំនួនគណនីសរុប: ៨១ | ចំនួនគណនីសរុប: ៨២ |

➢ **ចំណូលក្នុងស្រុកកើនឡើងដោយសារ÷**

- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអនុវត្តការប្រមូលចំណូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលចំណូលប្រចាំត្រីមាសទី៣ស្មើ ១០២,៥% ដែលស្មើនឹង ២៥,៧៩% នៃច្បាប់ថវិកាសម្រាប់ឆ្នាំ២០១៥ តាមទិន្នន័យអគ្គនាយកដ្ឋានរតនាគារជាតិ។ ទិន្នន័យផ្លូវការរបស់អគ្គនាយកដ្ឋានសាមី ការអនុវត្តការប្រមូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលប្រចាំត្រីមាសទី៣ស្មើ ១២១,០៦% ដោយសារការពង្រឹងការត្រួតពិនិត្យដើមទី កណ្តាលទី និងចុងទី និងការអនុវត្តផែនការសកម្មភាពនៃការប្រមូលពន្ធអាករ និងប្រាក់ពិន័យ លើយានយន្តមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធ និងអាករ។

- អគ្គនាយកដ្ឋានពន្ធដារអនុវត្តការប្រមូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលប្រចាំត្រីមាសទី៣ស្មើ ៩៦,៩០% ដែលស្មើនឹង ២៤,០២% នៃច្បាប់ថវិកាសម្រាប់ឆ្នាំ២០១៥។ ទិន្នន័យផ្លូវការរបស់អគ្គនាយកដ្ឋានសាមី ការអនុវត្តការប្រមូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលប្រចាំត្រីមាសទី៣ស្មើ ៩៨,៦៤% ហើយចំណូលដែលកើនឡើងលើសផែនការគឺចំណូលពន្ធលើប្រាក់ចំណេញ (១១០,២៨%) និងពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង (១៦៤,៩៨%)។

- អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុអនុវត្តការប្រមូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលប្រចាំត្រីមាសទី៣ ស្មើ១១៤,១៧% ដែលស្មើនឹង ២៨,៣៩% នៃច្បាប់ថវិកាសម្រាប់ឆ្នាំ២០១៥។ ទិន្នន័យផ្លូវការរបស់អគ្គនាយកដ្ឋានសាមី ការអនុវត្តការប្រមូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលប្រចាំត្រីមាសទី៣ស្មើ ១១៣,៤៣% ដោយសារមានក្រុមហ៊ុនកាស៊ីណូបើកថ្មី បានសុំអាជ្ញាបណ្ណ ដែលជាទូទៅ អគ្គនាយកដ្ឋានគ្រោងចំណូលពីអាជ្ញាបណ្ណតែត្រីមាសទី១ និងត្រីមាសទី៤ តែប៉ុណ្ណោះ។

- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អនុវត្តការប្រមូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលប្រចាំត្រីមាសទី៣ស្មើ១១៥,៤៦% ដែលស្មើនឹង ២៥,១៤% នៃច្បាប់ថវិកាសម្រាប់ឆ្នាំ២០១៥។ ទិន្នន័យផ្លូវការរបស់អគ្គនាយកដ្ឋានសាមី ការអនុវត្តការប្រមូលប្រចាំត្រីមាសទី៣ ធៀបនឹងផែនការប្រមូលប្រចាំត្រីមាសទី៣ស្មើ ១១៦,៧២% ដោយសារការកើនឡើងចំណូលពីផលព្រៃឈើដែលបានមកពីឈើស្ថិតនៅលើផ្ទៃដីសម្បទានដែលត្រូវឈូសឆាយ និងឈើខុសច្បាប់ដែលសមិទ្ធកិច្ចរឹបអូសបាន, ចំណូលពីសម្បទានរ៉ែ គឺក្រោយពីការធ្វើកំណែទម្រង់ដោយមានការដាក់ដេញថ្លៃខ្សាច់តាមដងទន្លេសម្រាប់ស្ពានគន្លងនាវាចរ និងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍

ដែលប្រតិបត្តិការទាំងអស់បានបិទបញ្ជីសព្វគ្រប់នៅខែមេសា និងខែឧសភា រួចផ្ញើតួលេខមកក្រសួងដើម្បីធ្វើការបែងចែកការបង់ចំណូលជូនថវិកាជាតិ។

➢ **ចំណាយថវិកាជាតិ÷**

- សម្រេចបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ គឺ ៥៧,៤% ខ្ពស់ជាង ១,៤% ធៀបនឹងការអនុវត្តដូចគ្នានៅឆ្នាំ២០១៤ បញ្ជាក់ថាអាណាប័កអាចបញ្ជាចំណាយ និងផែនការសាច់ប្រាក់ទាន់ពេលវេលា និងប្រសើរជាងមុន។

➢ **ចំណាយតាមប្រភេទ÷**

- សម្រាប់ចំណាយបៀវត្ស (បន្ទុកបុគ្គលិក) កាន់តែខិតទៅរកថវិកាដែលបានអនុម័តដោយអនុវត្តបាន ៧២,២% ក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ ទាបជាង២,៣% ធៀបនឹងការអនុវត្តដូចគ្នានៅឆ្នាំ២០១៤

- សម្រាប់ទំនិញ/សេវា អនុវត្តបាន ៤១,៣% ក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ ទាបជាង ១៣,៤% ធៀបនឹងការអនុវត្តដូចគ្នានៅឆ្នាំ២០១៤។

- សម្រាប់មូលធន អនុវត្តបាន ៤៩,០% ក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ ទាបជាង ១៣,៤% ធៀបនឹងការអនុវត្តដូចគ្នានៅឆ្នាំ២០១៤។

➢ **ចំណូលចរន្តត្រីមាសទី៣÷** ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០១៤ មានការកើនឡើង១៣,១% ដោយសារចំណូលសារពើពន្ធមានការកើនឡើង ១៦,០% ក្នុងនោះ÷

- ចំណូលគយ មានការកើនឡើង១០,១%
- ចំណូលពន្ធដារ មានកើនឡើង ២២,៣%
- ចំណូលសារពើពន្ធផ្សេងៗ មានកើនឡើង ២៦,១%

## ២. លទ្ធផលនៃសកម្មភាពគន្លឹះសម្រាប់បន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា

ក្រៅពីការតាមដានលើការអនុវត្តភាពជឿទុកចិត្តបាននៃថវិកា តាមរយៈសូចនាករសមិទ្ធកម្មគន្លឹះទាំង ៦ ខាងលើ សកម្មភាពគន្លឹះមួយចំនួនទៀតត្រូវបានដាក់ចេញ ដើម្បីអនុវត្តផង និងសម្រាប់តាមដានត្រួតពិនិត្យលើការពង្រឹងភាពជឿទុកចិត្តបាននៃថវិកាផង សំដៅគាំទ្រការធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពហិរញ្ញវត្ថុ ដែលជាគោលបំណងយុទ្ធសាស្ត្រនៃដំណាក់កាលទី២។

សកម្មភាពទាំងនេះ ត្រូវបានអនុវត្តក្នុងគោលបំណង ចំនួន ៤ និង ចង្កោមសកម្មភាព ចំនួន ១៤ ដើម្បីពង្រឹងភាពជឿទុកចិត្តបាននៃថវិកា ដែលជាផ្នែកមួយដ៏សំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ ថ្មី។

ការអនុវត្តសកម្មភាពដើម្បីពង្រឹងភាពជឿទុកចិត្តបាននៃថវិកាទាំងនោះ សម្រេចបានលទ្ធផលដូចតទៅ÷

### ២.១. ការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល

គោលបំណង ១១ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា មានចង្កោមសកម្មភាពចំនួន ៤។ ផ្អែកលើសកម្មភាពសម្រេចបាន គោលបំណងនេះសម្រេចបាន៦២% ក្នុងនោះចង្កោមសកម្មភាព ១១.១ សម្រេចបាន ៦០%, ១១.២ សម្រេច

បាន ៤៥%, ១១.៣ សម្រេចបាន ៨១% និង ១១.៤ សម្រេចបាន ៦២%។ ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាន នៃសូចនាករទាំង ៤ នៃចង្កោមសកម្មភាពទាំង៤ ឃើញថាមានសូចនាករ ៣ សម្រេចបានតាមគោលដៅ គឺ÷

១. ម៉ូដែលត្រូវបានរៀបចំឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយជាងមុន និងត្រូវបានទទួលការពិនិត្យដោយ នាយកដ្ឋានកិច្ចការសារពើពន្ធនៃមូលនិធិរូបិយវត្ថុ

២. បញ្ចប់ការងារកែទម្រង់ទិន្នន័យដែលមាននិងដាក់ឱ្យប្រើប្រាស់កម្មវិធីសម្រាប់ភ្ជាប់ទិន្នន័យដែលមានលក្ខណៈ

៣. សេចក្ដីព្រាងប្រកាសស្ដីពីការលុបចោលការចុះបញ្ជី (De-registration) ចំពោះសហគ្រាសដែលបាត់ខ្លួន មិនដាក់លិខិតប្រកាសដើម្បីគ្រប់គ្រងបញ្ជីអ្នកជាប់ពន្ធចរន្ត និងធ្វើឱ្យសុក្រឹតនូវបញ្ជីអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មពិតប្រាកដត្រូវបានបញ្ចប់ត្រឹមកម្រិត អ.ព.ដ។

ដោយឡែក សូចនាករ ៨ ទៀត មិនសម្រេចបានតាមគោលដៅ គឺ÷

១. របាយការណ៍វាយតម្លៃអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមិនទាន់រៀបចំ

២. ម៉ូដែលព្យាករណ៍របស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយមិនទាន់បានរៀបចំ

៣. សេចក្ដីព្រាងច្បាប់ស្ដីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងឧស្ម័ន មិនទាន់ត្រូវបានដាក់ក្នុងកិច្ចប្រជុំអន្តរក្រសួង

៤. សេចក្ដីព្រាងច្បាប់ស្ដីពីពន្ធលើប្រតិបត្តិការធនធានរ៉ែធម្មជាតិ ដូចជា មាស ត្បូងថ្ម ទង់ដែង មិនទាន់ត្រូវបានដាក់ក្នុងកិច្ចប្រជុំអន្តរក្រសួង

៥. ៨៥% នៃចំនួនអ្នកដែលបានគ្រោងត្រូវបានបញ្ចូលក្នុងរបបស្វ័យប្រកាស សម្រេចបានតែ៤៣%

៦. សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ មិនទាន់ត្រូវបានដាក់ឱ្យគណៈរដ្ឋមន្ត្រីអនុម័ត

៧. សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ មិនទាន់ត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រី

៨. សេចក្ដីព្រាងច្បាប់គ្រប់គ្រងកាស៊ីណូ មិនទាន់ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី

តាមលទ្ធផលខាងលើ បញ្ហាប្រឈមក្នុងការមិនសម្រេចបានតាមគោលដៅសូចនាករត្រីមាសទី៣ គឺ÷ ការរៀបចំផែនការសកម្មភាព និងដាក់សូចនាករ គឺមិនត្រូវបានពិភាក្សាពេញលេញជាមួយអង្គភាពអនុវត្ត នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើរពន្ធ ដែលទាមទារឱ្យមានការសហការ និងការកែលម្អការរៀបចំផែនការសកម្មភាព និងសូចនាករគោលដៅ។ ម្យ៉ាងទៀតអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ មានភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម និង អគ្គនាយកដ្ឋានពន្ធដារ ជួបប្រទះបញ្ហាប្រឈមការបណ្ដុះវប្បធម៌បង់ពន្ធនៃអ្នកជាប់ពន្ធដោយឆន្ទៈរបស់អ្នកជាប់ពន្ធតាមរបបម៉ៅការមិនចង់ចូលទៅក្នុងរបបពិត ដោយសារភាពសាំញ៉ាំក្នុងការប្រកាសពន្ធ, អ្នកជាប់ពន្ធតាមរបបម៉ៅការមានលក្ខណៈគ្រួសារ គ្មានបញ្ជីការគណនេយ្យត្រឹមត្រូវ និងអ្នកជាប់ពន្ធតាមរបបម៉ៅការមួយចំនួនមិនទាន់មានចំណេះដឹងខាងគ្រប់គ្រងបញ្ជីការគណនេយ្យ។ សម្រាប់ការរៀបចំការព្យាករណ៍ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា គឺកង្វះនូវជំនួយបច្ចេកទេស និងមន្ត្រីជំនាញនៅមានកម្រិត។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលនៃការអនុវត្តផែនការប្រមូលចំណូលដែលត្រូវសម្រេចបានក្នុងរង្វង់ +/-៥% គឺមិនទាន់សម្រេចបានទៅតាមគោលដៅនៅឡើយ។

ជារួម អាចសន្និដ្ឋានបានថា ការពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូលក្នុងឆ្នាំនៅមិនទាន់អនុវត្ត បានតាមគោលដៅដោយសារតែសុក្រឹតភាពនៃការព្យាករណ៍ និងភាពរលូននៃការប្រមូលចំណូលក្នុងឆ្នាំនៅមានកម្រិតទាប។ រីឯ ការអនុវត្តផែនការសកម្មភាពគាំទ្រដល់ការប្រមូលចំណូល គឺនៅមានភាពយឺតយ៉ាវ ដែលចាំបាច់ត្រូវពង្រឹងការសហការជាមួយអង្គភាពពាក់ព័ន្ធ និងការចូលការអនុវត្តសកម្មភាពកែទម្រង់របស់ខ្លួន។

## ២.២. ការពង្រឹងការគ្រប់គ្រងបំណុល

ការពង្រឹងការគ្រប់គ្រងបំណុល ជាគោលបំណងទី១២ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា និងមានចង្កោមសកម្មភាពចំនួន ៣។ ផ្អែកលើសកម្មភាពសម្រេចបាន ក្នុងត្រីមាសទី ៣ នេះ អ.គ.ហ. ពិនិត្យឃើញថាមានតែចង្កោមសកម្មភាពមួយប៉ុណ្ណោះ ដែលសម្រេចបាន ១០០% ទៅតាមគោលដៅសូចនាករគឺ ចង្កោមសកម្មភាព ១២.១ ប៉ុន្តែចំពោះចង្កោមសកម្មភាព ១២.២ ដែលអគ្គនាយកដ្ឋានរាយការណ៍ថាសម្រេចបាន ១០០% គឺមិនអាចវាស់វែងបាន នៅក្នុងត្រីមាសទី ៣ ទេ ដោយហេតុថាមិនមានសកម្មភាពគ្រោងអនុវត្ត នៅក្នុងត្រីមាសនេះ និងបានសម្រេចជោគជ័យរួចរាល់នៅត្រីមាសទី ២។ម្យ៉ាងវិញទៀត ចំពោះចង្កោមសកម្មភាព ១២.៣ ដែលមានសកម្មភាពគ្រោងអនុវត្តក្នុងត្រីមាសទី៣នេះ មិនទាន់មានរបាយការណ៍ថាសម្រេចជោគជ័យនៅឡើយទេ។

ទន្ទឹមនឹងនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសកម្មភាព សម្រាប់ត្រីមាសទី ៣ នេះ ឃើញថាមានសូចនាករមួយ សម្រេចបានតាមគោលដៅគឺ សេចក្តីព្រាងប្រកាសលើកទី៣ ស្តីពី គោលការណ៍និងនីតិវិធីសម្រាប់ប្រតិបត្តិការគ្រប់គ្រងបំណុលសាធារណៈ និងនីតិវិធីនៃការធានារបស់រដ្ឋត្រូវបានរៀបចំ។ ចំណែកសូចនាករមួយទៀត ដែលពាក់ព័ន្ធនឹងសេចក្តីព្រាងចុងក្រោយព្រឹត្តិប័ត្រត្រូវបានរៀបចំ មិនបានសម្រេចតាមគោលដៅឡើយ។

ដូចនេះ ជាសន្និដ្ឋានរួម ការពង្រឹងការគ្រប់គ្រងបំណុល នៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៥។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវខិតខំបន្ថែមទៀត ដើម្បីឱ្យការគ្រប់គ្រងបំណុលកាន់តែមានប្រសិទ្ធភាព និងសម្រេចតាមគោលដៅកម្មវិធីកែទម្រង់ដំណាក់កាលទី២ថ្មី ដែលនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៥។

## ២.៣. ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី

ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី ដែលជាគោលបំណង ១៣ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកាមានចង្កោមសកម្មភាពចំនួន ៤។ បើផ្អែកលើសកម្មភាពសម្រេចបាន គោលបំណងនេះសម្រេចបាន ៩៥% ក្នុងនោះចង្កោមសកម្មភាព ១៣.១ សម្រេចបាន ១០០%, ចង្កោមសកម្មភាព ១៣.២ សម្រេចបាន ១០០%, ១៣.៣ សម្រេចបាន ៨៧% និងចង្កោមសកម្មភាព ១៣.៤ សម្រេចបាន ៩៣%។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣ នេះ ឃើញថាមាន ២ សូចនាករសម្រេចបានតាមគោលដៅ គឺ÷

១. គណនីក្រៅប្រព័ន្ធ “TSA” នៅតាមធនាគារជាតិនិងធនាគារពាណិជ្ជដែលមិនមានការអនុញ្ញាតពី កសហវ ត្រូវបានបន្តបិទ, គណនីទោលរតនាគារនៅរាជធានី-ខេត្ត ត្រូវបានតាមដាននិងកំណត់ច្បាស់លាស់ និង សិក្សា

ប្រភេទគណនីគម្រោងរបស់ដៃគូអភិវឌ្ឍន៍

២. ការទូទាត់ថ្នាក់កណ្ដាល សម្រេចបាន១០០% តាមប្រព័ន្ធធនាគារ, ប្រព័ន្ធទូទាត់តាម E-transfer ត្រូវបានសិក្សា និងការបើកបៀវត្សតាមប្រព័ន្ធធនាគារត្រូវបានពង្រឹង។

ដោយឡែក សូចនាករពីរទៀតមិនសម្រេចបានតាមគោលដៅ គឺ ទី១ ការកែលម្អរបាយការណ៍ ផែនការសាច់ប្រាក់ប្រចាំថ្ងៃ សប្ដាហ៍ ខែ និងត្រីមាស និងការពិនិត្យតាមដានការគ្រប់គ្រងសាច់ប្រាក់ ពីព្រោះវគ្គបណ្ដុះបណ្ដាលស្ដីពីរបៀបប្រើប្រាស់ប្រព័ន្ធ Online Web-based Application ដល់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ នឹងរៀបចំធ្វើនៅត្រីមាសទី៤ ឆ្នាំ២០១៥ ដោយមូលហេតុមានការកែតម្រូវនិងបន្ថែមរូបរាងច្រើនខុសពីការគ្រោង និងចំណាយរយៈពេលសាកល្បងយូរជាងការគ្រោងទុក ដើម្បីឱ្យប្រព័ន្ធនោះរួចរាល់និងមានភាពត្រឹមត្រូវ មុននឹងបើកវគ្គបណ្ដុះបណ្ដាលដល់ក្រសួង-ស្ថាប័ន ក្នុងរយៈពេល ៩ខែកន្លងមកនេះ គម្លាតលំហូរសាច់ប្រាក់ចូលលំអៀងជាមធ្យម ៩,៤២ % និង លំហូរសាច់ប្រាក់ចេញលំអៀងជាមធ្យម ១៤,០៣% រីឯកំហុសឆ្គងការព្យាករណ៍ចំណូលនិងចំណាយថវិកាស្ថិតក្នុងចន្លោះហូរសាច់ប្រាក់ចូល ៣,៦ %< X < ១៥,២% និងលំហូរសាច់ប្រាក់ចេញលំអៀងក្នុងចន្លោះ -៧,៧%< x < -២០,៣% ។ ទី២ ការអនុវត្តផែនការសមាហរណកម្មកំពុងដំណើរការល្អប្រសើរ ប៉ុន្តែមិនទាន់សម្រេចជាស្ថាពរ ១០០%នៅឡើយដោយសារកង្វះពេលវេលាក្នុងការសាកល្បងតភ្ជាប់នេះត្រូវការសហការ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានថវិកាតាមប្រព័ន្ធ DMFAS ក្នុងរយៈពេលរៀបចំវេចខ្ចប់កញ្ចប់ថវិការបស់ក្រសួងស្ថាប័នសម្រាប់ឆ្នាំ ២០១៦។

ដូចនេះ អាចសន្និដ្ឋានបានថាការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនីធនាគារនៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៥ និងខិតជិតទៅរកស្ថិរភាពតាមគោលដៅដោយសារប្រព័ន្ធ Online Web-based Application បានរៀបចំរួចរាល់ដោយត្រៀមរៀបចំវគ្គបណ្ដុះបណ្ដាលដល់ក្រសួង-ស្ថាប័នយ៉ាងយឺតបំផុតត្រឹមត្រីមាសទី៤ ហើយប្រសិទ្ធភាពការព្យាករណ៍សាច់ប្រាក់ត្រូវបានធានាបានឆ្ពោះទៅកាន់សុក្រឹតភាពជាងមុន។ លើសពីនេះការការទូទាត់ប្រាក់បៀវត្សរ៍តាមប្រព័ន្ធធនាគារ និងការគ្រប់គ្រងគណនីក្រៅប្រព័ន្ធ “TSA” នឹងក្លាយជាការងារប្រចាំថ្ងៃរបស់អគ្គនាយកដ្ឋានរតនាគារជាតិ។

## ២.៤. ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ

គោលបំណង ១៤ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា មានចង្កោមសកម្មភាពចំនួន ៣។ ផ្អែកលើសកម្មភាពសម្រេច បាន គោលបំណងនេះសម្រេចបាន ៨០% ក្នុងនោះ ចង្កោមសកម្មភាព ១៤.១ សម្រេចបាន ៦៦%, ចង្កោមសកម្មភាព ១៤.២ សម្រេចបាន ៧៥% និង ១៤.៣ សម្រេចបាន ១០០%។

បើពិនិត្យលើលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣នេះ ឃើញថាពុំមានសូចនាករសម្រេចបានតាមគោលដៅនោះឡើយ។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣ នេះ ឃើញថា មានមួយសូចនាករសម្រេចបានតាមគោលដៅ គឺ÷

១. ការអនុវត្តទូទាត់ចំណាយតាមផែនការចំណាយ ដោយសារអគ្គនាយកដ្ឋានរតនាគារជាតិបានបន្តពង្រឹងគុណភាពនិងប្រសិទ្ធភាពក្នុងការត្រួតពិនិត្យអាណត្តិបើកប្រាក់ និងលិខិតយុត្តិការចំណាយដើម្បីទូទាត់បានទាន់ពេលវេលា និងត្រឹមត្រូវស្របតាមនិតីវិធីហិរញ្ញវត្ថុ។

ដោយឡែក សូចនាករពីរទៀតមិនសម្រេចបានតាមគោលដៅ គឺ

១. សេចក្តីព្រាងអនុក្រឹត្យ ប្រកាសនានាត្រូវបានអនុម័ត និងផ្សព្វផ្សាយ ជាក់ស្តែងសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ា និងវិវាទលទ្ធកម្ម ទើបតែបញ្ជូនទៅក្រុមប្រឹក្សានីតិកម្មនៃ កសហវ ដែលយឺតជាងសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាសដែលបានដាក់ចេញដោយអគ្គនាយកដ្ឋានលទ្ធកម្មចំនួន ២ ត្រីមាសដែលត្រូវបញ្ជូនទៅដល់ទីស្តីការគណៈរដ្ឋមន្ត្រី។ ចំណែកឯប្រកាសដែលមិនទាន់សម្រេចបានតាមគោលដៅគឺប្រកាសស្តីពីការកែប្រែតម្លៃកិច្ចសន្យាមិនទាន់បានរៀបចំសេចក្តីព្រាង និងប្រកាសស្តីពីបែបបទ និងការកំណត់ថ្លៃលក់សារដេញថ្លៃ និងប្រកាសស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តបានដាក់ប្រជុំពិនិត្យពិភាក្សាក្នុងអគ្គនាយកដ្ឋានរួចរាល់ប៉ុន្តែនៅពុំទាន់ដាក់ជូនរដ្ឋមន្ត្រី កសហវ ចុះហត្ថលេខានៅឡើយ។ ក្នុងនោះផងដែរសេចក្តីព្រាងសៀវភៅការអនុវត្តវិធាន និងបទប្បញ្ញត្តិពីលទ្ធកម្មសាធារណៈ (IRRPP) ទើបសម្រេចបានលើការកែសម្រួលបាន បីជំពូកតែប៉ុណ្ណោះដោយសារសម្ពាធពេលវេលា និងឆន្ទៈចូលរួមពីមន្ត្រីពាក់ព័ន្ធក្នុងអគ្គនាយដ្ឋានលទ្ធកម្មសាធារណៈនៅមានកម្រិត។ លើសពីនេះ ការកែលម្អស្តង់ដារឯកសារដេញថ្លៃ (SBDs) មានវឌ្ឍនភាពមួយចំនួនតែមិនសម្រេចបានសូចនាករយឺតជាងផែនការដែលបានដាក់ចេញ។ ជាពិសេសទៅទៀតអ្វីដែលចង្អោមសកម្មភាពនេះគួរពិចារណា និងបន្តជំរុញបន្ថែមទៀតនោះគឺ ការបង្កើតប្រព័ន្ធគ្រប់គ្រងលទ្ធកម្មសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (PPMIS) គួរតែបញ្ចប់សេចក្តីព្រាង PPMIS ក្នុងកម្រិតអគ្គនាយកដ្ឋានមុនដាក់ឱ្យអនុម័តដោយថ្នាក់ដឹកនាំ។

២. សេចក្តីព្រាងចុងក្រោយ operational manual សម្រាប់ការរៀបចំ និងអនុវត្តគម្រោងវិនិយោគ និងការងារជួសជុលថែទាំត្រូវបានរៀបចំបានត្រឹមសេចក្តីព្រាងលើកទី២ឯកសារគោលនយោបាយនិងបានដាក់ពិភាក្សាផ្តល់យោបល់ចំនួន០១ លើកក្នុងអគ្គនាយកដ្ឋានថវិកា។ លើសពីនេះ ថវិកាបុរេប្រទានត្រូវបានទូទាត់ ៧០%តាមសូចនាករគន្លឹះប្រចាំត្រីមាសទី៣ ជាក់ស្តែងក្នុងថវិកាបុរេប្រទានត្រូវបានទូទាត់ចំនួន ១៨១,៩៨៩ លានរៀល នៃបុរេប្រទាន សរុបចំនួន ៥០៤,២៦៦ លានរៀល ក្នុងឆ្នាំ២០១៥ ដែលត្រូវជា ៣៦% ដូចនេះអគ្គនាយកដ្ឋានថវិកាត្រូវពង្រឹងការទូទាត់បន្ថែមនៅត្រីមាសទី៤បន្តទៅមុខឱ្យបានយ៉ាងតិច ៧០%។

ដូចនេះ អាចសន្និដ្ឋានបានថា ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ មិនទាន់សម្រេចបានតាមគោលដៅកំណត់ សម្រាប់ត្រីមាសទី៣នេះទេ ដោយហេតុថា (១)យន្តការត្រួតពិនិត្យផ្ទៃក្នុងអគ្គនាយកដ្ឋានលើសកម្មភាពនិងការកំណត់សូចនាករនៅមានកម្រិត ដើម្បីឆ្លើយតបទៅនឹងចង្អោមសកម្មភាពនិងគោលបំណងដែលបានកំណត់ (២) កង្វះកិច្ចសហការក្នុងការធ្វើបច្ចុប្បន្នភាពសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ (IRRPP)ដោយធ្វើសុខដុមនីយកម្មជាមួយស្តង់ដារនីតិវិធីរួម (SOPs) ដែលតម្រូវឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈសហការជាមួយអគ្គនាយកដ្ឋានថវិកាក្នុងការរៀបចំ (៣) ការយឺតយ៉ាវក្នុងបង្កើតប្រព័ន្ធគ្រប់គ្រងលទ្ធកម្ម

សាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (PPMIS) និង (៤) សេចក្តីព្រាងចុងក្រោយ operational manual និងថវិកាបុរេប្រទានត្រូវបានទូទាត់គួរបន្តជំរុញការរៀបចំ និងទូទាត់។

## ផ្នែកទី២: គណនេយ្យភាពហិរញ្ញវត្ថុ

នៅក្នុង CAP 2 New ផ្នែកទី២ គណនេយ្យភាពហិរញ្ញវត្ថុ ត្រូវបានអនុវត្តតាមរយៈគោលបំណងចំនួន គឺការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី, ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី, ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព, ការដាក់ឱ្យអនុវត្តឧបករណ៍និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព, ពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា និងពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច។ គោលបំណងទាំងនេះ ត្រូវបានគាំទ្រដោយ ចង្កោមសកម្មភាពចំនួន ២៥។

បើផ្អែកលើគោលបំណងដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៨៣% ដែលក្នុងនោះគ្មានគោលបំណងណាមួយសម្រេចបាន ១០០% ទេ, មានគោលបំណងចំនួន ៤ សម្រេចបានលើស ៨០%, គោលបំណងចំនួន ១ សម្រេចបានក្រោម៨០% និងគោលបំណងចំនួន ១ មិនអាចវាស់វែងបាន។ ក្នុងចំណោមចង្កោមសកម្មភាពទាំង២៥ មានចង្កោមសកម្មភាពចំនួន ១៥ សម្រេចបានលើស ៨០%, ចង្កោមសកម្មភាពចំនួន ៤ សម្រេចបានលើស ៥០%, ចង្កោមសកម្មភាពចំនួន ២ សម្រេចបានទាបជាងឬស្មើ ៥០% និងចង្កោមសកម្មភាពចំនួន ៣ មិនអាចធ្វើការវាស់វែងបាន។

### ១. ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី

គោលបំណង ២១ នៃគណនេយ្យភាពហិរញ្ញវត្ថុ មានចង្កោមសកម្មភាពចំនួន ៤។ បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងត្រីមាសទី ៣ ឆ្នាំ២០១៥ គោលបំណងនេះ សម្រេចបាន ប្រហែល ៩០%។ ក្នុងនោះ ចង្កោមសកម្មភាព ២១.១ សម្រេចបាន ៩៣% , ចង្កោមសកម្មភាព ២១.២ សម្រេចបាន ៩៥% , ចង្កោមសកម្មភាព ២១.៣ សម្រេចបាន ១០០% និងចង្កោមសកម្មភាព ២១.៤ សម្រេចបាន ៧០%។

ទន្ទឹមនឹងនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសកម្មភាព សម្រាប់ត្រីមាសទី ៣ នេះ ឃើញថា មានសូចនាករ ៣ សម្រេចបានតាមគោលដៅគឺ÷

១. គ្រប់ទិន្នន័យ និងប្រតិបត្តិការក្រៅរតនាគារជាតិ ត្រូវបានបន្តធ្វើសមាហរណកម្ម ទៅក្នុងប្រព័ន្ធគណនេយ្យរដ្ឋ

២. តារាងចំណាត់ថ្នាក់រដ្ឋបាលត្រូវបានពិនិត្យ និងកែសម្រួល និងត្រៀមប្រកាសដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រ

៣. ព័ត៌មានស្តីពីរចនាសម្ព័ន្ធមុខងារនិងសេវារបស់ក្រសួង ស្ថាប័ន ត្រូវបានធ្វើបច្ចុប្បន្នភាព

ក្រៅពីនេះ មានសូចនាករពីរដែលមិនទាន់សម្រេចបានពេញលេញ គឺ÷

១. ការដាក់ឱ្យប្រើប្រាស់ ប្រកាសកែសម្រួលចំណាត់ថ្នាក់សេដ្ឋកិច្ច សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្នសេចក្តីព្រាងប្រកាសនេះ ត្រូវបានរៀបចំរួចរាល់ ប៉ុន្តែកំពុងពិនិត្យពិភាក្សាជាមួយអ្នកពាក់ព័ន្ធ។

២. ការរៀបចំរបាយការណ៍ IPSAS និងការបន្តរៀបចំស្តង់ដារគណនេយ្យសម្រាប់មូលដ្ឋានសាច់ប្រាក់ IPSAS។ បញ្ហាប្រឈម គឺមានការលំបាកក្នុងការប្រមូលនិងផ្ទេរទិន្នន័យបច្ចុប្បន្ន ទៅក្នុងរបាយការណ៍ IPSAS និងប្រព័ន្ធទិន្នន័យបច្ចុប្បន្នពុំឆ្លើយតបនឹងតម្រូវការរបស់របាយការណ៍ IPSAS។

ជាសន្និដ្ឋាន ការត្រៀមលក្ខណៈដើម្បីឱ្យអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី នៅតែរក្សាបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ បើទោះបីជាមានសូចនាករមួយចំនួនមិនទាន់សម្រេចបានពេញលេញតាមគោលដៅក៏ដោយ។

## ២. ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី

ការកែលម្អដំណើរការនិងប្រតិបត្តិការអនុវត្តថវិកា ដែលត្រូវបានអនុវត្តក្នុងគោលបំណង ២៤ នៃ CAP 2 ត្រូវបានកែសម្រួលមកជាគោលបំណង ២២. ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី ក្នុង CAP 2 New។ ជាក់ស្តែង ការអនុវត្តគោលបំណងទី ២២. សម្រាប់ត្រីមាសទី៣ នេះ ក៏មិនមានភាពខុសប្លែកគ្នាខ្លាំងដែលគួរឱ្យកត់សម្គាល់នោះដែរពីការអនុវត្តប្រចាំត្រីមាសទី២ ឆ្នាំ២០១៥ តាមរយៈការដាក់ចេញនូវចង្កោមសកម្មភាព និងសូចនាករ ជាពិសេសការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS។ ម្យ៉ាងទៀត ចង្កោមសកម្មភាពនៃគោលបំណងនេះ មានចំនួន ៨ ក្នុង CAP 2 ត្រូវតម្រឹមមកចំនួន ៧ ក្នុង CAP 2 NEW ដែលរួមមាន÷ ២២.១. បន្តកាត់បន្ថយពេលវេលាសម្រាប់ការ ស្នើសុំធានាចំណាយនិងការទូទាត់នៅក្នុងក្រសួង-ស្ថាប័ន, ២២.២. កែលម្អដំណើរការនៃប្រតិបត្តិការនៅក្នុង កសហវ/ ក្រសួងស្ថាប័ន ដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍនៃប្លង់គណនី និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ គណនីធនាគារជាប្រចាំ, ២២.៣. បង្កើនកម្រិតយល់ដឹងភាពជាម្ចាស់ការចូលរួម និងសមត្ថភាពផ្នែក FMIS ដល់ កសហវ ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ, ២២.៤. កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ដោយរួម ទាំងនៅ កសហវ ក្រសួងស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ, ២២.៥. រៀបចំផែនការអនុវត្តរួម (ការសាកល្បងនិងការ ពង្រីក) ដោយរួមបញ្ចូល កសហវ ក្រសួងស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ, ២២.៦. រៀបចំផែនការ និងវគ្គបណ្តុះបណ្តាល ព្រមទាំងឯកសារបណ្តុះបណ្តាលសម្រាប់ការបន្តបណ្តុះបណ្តាលដល់គ្រប់មន្ត្រីដែលពាក់ព័ន្ធនឹង FMIS នៅ កសហវ ក្រសួងស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ និង ២២.៧. ការអនុវត្តសាកល្បងជំហានដំបូងនិងពង្រីកការអនុវត្ត FMIS (ម៉ូឌុលស្នូល និងម៉ូឌុលសម្រាប់ថវិកា)។

សម្រាប់ការអនុវត្តប្រចាំត្រីមាសទី៣ គោលបំណងនេះត្រូវបានអនុវត្ត និងសម្រេចបាន ៨៥% ធៀបនឹងសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាសទី៣ ដែលចង្កោមសកម្មភាព ២២.១. សម្រេចបាន ៩៦%, ចង្កោមសកម្មភាព ២២.២. សម្រេចបាន ៨៩%, ចង្កោមសកម្មភាព ២២.៣. សម្រេចបាន ៨១%, ចង្កោមសកម្មភាព ២២.៤. សម្រេចបាន ៨១%, ចង្កោមសកម្មភាព ២២.៥. សម្រេចបាន ៩១%, ចង្កោមសកម្មភាព ២២.៦. សម្រេចបាន ១០០% និងចង្កោមសកម្មភាព ២២.៧. សម្រេចបាន ៧៦%។

តាមរយៈលទ្ធផលនេះ យើងអាចកំណត់បានថា សម្រាប់ការអនុវត្តប្រចាំត្រីមាសទី៣ សង្កោមសកម្មភាព ២២.១, ២២.២, ២២.៤, និង ២២.៦ នៅតែរក្សាបាននូវវឌ្ឍនភាពជាសារវន្ត បើប្រៀបធៀបនឹងការអនុវត្តប្រចាំត្រីមាសទី២ កន្លងមក

ដោយក្នុងចំណោម ៤១ សកម្មភាពនៃគោលបំណងនេះ សកម្មភាពដែលបានបញ្ចប់ និងសម្រេចបាន ១០០% មានចំនួនតែ ១៧ សកម្មភាព ដោយមូលហេតុ បរិបទចំណាយ ថ្មីស្របតាមកម្មវិធី FMIS ត្រូវបានត្រួតពិនិត្យ និងរៀបចំ, ប្រាក់សោធននិវត្តត្រូវបានបើកផ្តល់ទាន់ពេលវេលា, ការលើកកម្ពស់លើសមត្ថភាពមន្ត្រីពាក់ព័ន្ធ មានលក្ខណៈប្រសើរតាមរយៈការបានទទួលវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព ជាដើម។ ដោយឡែក សកម្មភាពមួយចំនួន គួរត្រូវពង្រឹង និងកែលម្អបន្ថែម ដូចជាការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS មិនទាន់បានទូលំទូលាយនៅឡើយ និងមិនទាន់បានគ្រប់គោលដៅ ដោយសារផែនការដំឡើងប្រព័ន្ធ FMIS ត្រូវបានផ្លាស់ប្តូរ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ផ្អែកលើសកម្មភាព និងសូចនាករដែលបានកំណត់ក្នុងផែនការសកម្មភាពដំណាក់កាលទី២ ថ្មី របស់អគ្គនាយកដ្ឋាន/អង្គភាព ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មីមានស្ថានភាពកាន់តែល្អប្រសើរ ដែលអាចបង្កើតជាលទ្ធភាពក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពដើម្បីឈានទៅសម្រេចបានតាមគោលដៅ។ ទោះជាយ៉ាងនេះក្តី គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានចង្កោមសកម្មភាពពាក់ព័ន្ធនឹងគោលបំណងនេះ គួរបង្កើនការយកចិត្តទុកឱ្យខ្ពស់បន្ថែមទៀត ដើម្បីសម្រេចឱ្យបាននូវការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី ស្របជាមួយការដាក់ឱ្យអនុវត្ត FMIS កាលពីខែកក្កដា កន្លងទៅ។ លើសពីនេះទៀត គ្រប់សូចនាករដែលបានដាក់ចេញតាមសកម្មភាពនីមួយៗ ត្រូវបានត្រួតពិនិត្យ និងកែលម្អដើម្បីធានាការសម្រេចបាននៅគោលដៅសូចនាករគន្លឹះប្រចាំឆ្នាំ។

## ៣. ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព

គោលបំណង២៣ នៃគណនេយ្យភាពហិរញ្ញវត្ថុ មានចង្កោមសកម្មភាពអនុវត្តចំនួន ៤។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៥៣% ក្នុងនោះចង្កោមសកម្មភាព ២៣.១ សម្រេចបាន៧៥%, ២៣.៥ សម្រេចបាន៣២% និងចង្កោមសកម្មភាព ២៣.៣ និង២៣.៤ មិនអាចធ្វើការវាស់វែងបាន។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣នេះឃើញថា សូចនាករទាំងអស់មិនអាចសម្រេចបានតាមគោលដៅ គឺ៖

១. អនុវត្តផែនការសកម្មភាពដើម្បីកែលម្អបទដ្ឋានគណនេយ្យបច្ចុប្បន្ន និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋានសាច់ប្រាក់ត្រូវបានរៀបចំរួចរាល់ និងដាក់បញ្ចូលក្នុង FMIS ជាក់ស្តែងអគ្គនាយកដ្ឋានរតនាគារជាតិមិនទាន់បានជ្រើសរើសទីប្រឹក្សាក្នុងការរៀបចំប្រព័ន្ធស្តង់ដារគណនេយ្យរដ្ឋបាលសាធារណៈ ដែលមានលក្ខណៈជាអន្តរជាតិ IPSAS នៅឡើយទេដែលទាមទារពេលពេលវេលាបន្ថែមក្នុងការជម្រុញការងារនេះឱ្យមានប្រសិទ្ធភាព។

២. ប្រមូលបញ្ជីសារពើភ័ណ្ឌថ្មីទូទាំងប្រទេស នៅមានកម្រិតដោយសារការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ទាំងប្រាំបួនខែ ដែលបានទទួលមានចំនួន ៩៦៣ អង្គភាព លើ១១៥២អង្គភាពទូទាំងប្រទេស ប្រហែល ៨៤%តែប៉ុណ្ណោះ លើសពីនេះការរៀបចំប្រព័ន្ធទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមិនទាន់ស្នើសុំតម្លើងនៅឡើយពីព្រោះពុំទាន់បានស្នើសុំប្រភពថវិកានៅឡើយ។

ដូចនេះ អាចសន្និដ្ឋានបានថា ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព មិនទាន់អាចធានានិងរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៥ នៅឡើយទេ ដោយហេតុថា (ទី១) សកម្មភាពដែលអនុវត្តគាំទ្រដល់ការសម្រេចបាននូវចង្កោមសកម្មភាព ២៣.៣ ពុំត្រូវបានរៀបចំ (ទី២) ការអនុវត្តផែនការសកម្មភាពដើម្បីកែលម្អបទដ្ឋានគណនេយ្យបច្ចុប្បន្ន និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋានសាច់ប្រាក់មិនទាន់បានរៀបចំរួចរាល់ទាំងស្រុង និងដាក់បញ្ចូលក្នុង FMIS នៅឡើយ និង (ទី៣) ការប្រមូលបញ្ជីសារពើភ័ណ្ឌថ្មីទូទាំងប្រទេសមិនទាន់សម្រេចបានតាមគោលដៅ ព្រមទាំងប្រព័ន្ធទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមិនទាន់ស្នើសុំតម្លើងនៅឡើយ។

## ៤. ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព

គោលបំណង២៤ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ មានចង្កោមសកម្មភាពចំនួន ៤។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៨៨% ក្នុងនោះចង្កោមសកម្មភាព ២៤.១ សម្រេចបាន ៥០% និងចង្កោមសកម្មភាព២៤.២, ២៤.៣ និង២៤.៤ សម្រេចបាន ១០០%។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣នេះ ឃើញថាមានសូចនាករមួយ មិនសម្រេចបានតាមគោលដៅឡើយ គឺ គោលការណ៍ណែនាំស្តីពីការរៀបចំឱ្យមានទណ្ឌកម្មសម្រាប់ការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប ត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ដូចនេះ អាចសន្និដ្ឋានបានថាការដាក់ឱ្យអនុវត្តឧបករណ៍និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព ពុំទាន់អាចធានានិងរក្សាបាន នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៥នេះ នៅឡើយទេ ដោយហេតុថា សកម្មភាពពាក់ព័ន្ធគាំទ្រដល់ការបង្កើតឱ្យមានទណ្ឌកម្មសមស្របចំពោះកំហុសឆ្គង ឬ ការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព មិនត្រូវបានអនុវត្តតាមគោលដៅដែលបានកំណត់។

## ៥. ពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា

គោលបំណង ២៥ នៃគណនេយ្យភាពហិរញ្ញវត្ថុ មានចង្កោមសកម្មភាពចំនួន ២។ អគ្គនាយកដ្ឋាន បានរាយការណ៍ថា សម្រេចបានចង្កោមសកម្មភាពទាំងពីរ ប៉ុន្តែ អ.គ.ហ. ពិនិត្យឃើញថា មិនអាចវាស់វែងបានឡើយ ដោយហេតុថាមិនមានសកម្មភាពគ្រោងអនុវត្ត ក្នុងត្រីមាសទី ៣ នេះទេ។

ចំពោះចង្កោមសកម្មភាព ២៥.១ ដែលមានសូចនាករពាក់ព័ន្ធនឹងការពិនិត្យនិងកែសម្រួលគោលការណ៍ណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងលក្ខណៈវិនិច្ឆ័យសម្រាប់វិធីសាស្ត្រចាត់ថ្នាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា មិនទាន់សម្រេចបានតាមគោលដៅកំណត់ទេរហូតដល់ត្រីមាសទី៣ នេះ ដោយសារសម្ពាធពេលវេលា។ តាមផែនការដាក់ចេញដោយអគ្គនាយកដ្ឋាន សកម្មភាពនេះគួរត្រូវបញ្ចប់តាំងពីត្រីមាសទី២ ឆ្នាំ២០១៥។ ចំណែកចង្កោមសកម្មភាព ២៥.២ ដែលមានសូចនាករពាក់ព័ន្ធនឹងការផ្សព្វផ្សាយ សារាចរស្តីពីផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ដើម្បី

ធ្វើសមាហរណកម្មថវិការវាងថវិកាចរន្ត ថវិកាមូលធន និងថវិកាសហគ្រាសសាធារណៈ គឺសម្រេចបាន ១០០% នៅត្រីមាសទី២ រួចហើយ។

ជារួម ការពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនៃថវិកា នៅតែធានាបានក្នុងត្រីមាសទី៣ នេះ បើទោះបីជាមានសូចនាករមួយ នៅមិនទាន់សម្រេចបានតាំងពីត្រីមាសទី២ ក៏ដោយ។ ប៉ុន្តែនេះគឺដោយសារមានសម្ពាធពេលវេលាក្នុងការអនុវត្ត និងស្នើឱ្យមានការចង្អុលបង្ហាញបន្ថែមពីថ្នាក់ដឹកនាំ។

## ៦. ពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច

គោលបំណងទី៦ ការពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច បានកំណត់ចេញនូវចង្កោមសកម្មភាពចំនួន៤ ដោយផ្ដោតជាសំខាន់ទៅលើការពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច តាមរយៈចង្កោមសកម្មភាព ២៦.១. ដំណើរការពេញលេញអង្គភាពសវនកម្មផ្ទៃនៅគ្រប់ក្រសួងស្ថាប័ន, ២៦.២. កែលម្អយន្តការ ដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផលសវនកម្ម និងអធិការកិច្ចនៅតាមបណ្ដាអង្គភាពថវិកា, ២៦.៣. រៀបចំនិងកែលម្អផែនការសវនកម្ម/អធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួងស្ថាប័ន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យដែលបានផ្ដល់អនុសាសន៍ដោយកសហវ និង ២៦.៤. កសហវ ពិនិត្យមើលឡើងវិញពីភាពគ្រប់គ្រាន់នៃគំរូរបាយការណ៍សវនកម្ម/អធិការកិច្ច និងធ្វើការកែលម្អ។

សម្រាប់ការអនុវត្តប្រចាំត្រីមាសទី៣ គោលបំណងនេះត្រូវបានអនុវត្ត និងសម្រេចបាន ១០០% ធៀបនឹងសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាសទី៣ ដែលចង្កោមសកម្មភាព ២៦.១. សម្រេចបាន ១០៤%, ចង្កោមសកម្មភាព ២៦.២. សម្រេចបាន ៨៨%, ចង្កោមសកម្មភាព ២៦.៣. សម្រេចបាន ១០០% និងចង្កោមសកម្មភាព ២៦.៤. សម្រេចបាន ១០៧%។ តាមរយៈលទ្ធផលនេះ យើងអាចកំណត់បានថា សម្រាប់ការអនុវត្តប្រចាំត្រីមាសទី៣ សង្កោមសកម្មភាពទាំង៤ នៃគោលបំណងនេះនៅតែរក្សាបាននូវវឌ្ឍនភាពជាសារវន្ត បើប្រៀបធៀបនឹងការអនុវត្តប្រចាំត្រីមាសទី២ កន្លងមក ដោយក្នុងចំណោម ៣០ សកម្មភាពនៃគោលបំណងនេះ សកម្មភាពដែលបានបញ្ចប់ និងសម្រេចបាន ១០០% មានចំនួន ១៩ សកម្មភាព ដោយមូលហេតុ ការអនុវត្តសវនកម្មផ្ទៃក្នុងបានលើសផែនការ និងអគ្គាធិការដ្ឋានបានបញ្ចប់យន្តការធ្វើអធិការកិច្ច និងបានចងក្រងកម្រងលិខិតគតិយុត្តក្នុងវិស័យសង្គមកិច្ច ជាដើម។ ដោយឡែកនៅមានសកម្មភាពមួយចំនួនមិនធ្វើបានល្អ ដូចជាការជំរុញការអនុវត្តអនុសាសន៍របស់ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងមិនទាន់បានគ្រប់គោលដៅដែលបានដាក់ចេញ ប៉ុន្តែទោះជាយ៉ាងណាក្ដី ក្នុងគោលបំណងនេះ យើងឃើញថាការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចត្រូវបានពង្រឹង និងកែលម្អគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងត្រីមាសទី៣នេះ។

ជារួម ដោយផ្អែកលើការអនុវត្តសកម្មភាព គឺអាចសន្និដ្ឋានបានថាការពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចត្រូវបានពង្រឹង និងពង្រីក នៅតាមក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ដោយគិតត្រឹមត្រីមាសទី៣នេះ ក៏ប៉ុន្តែនៅមានការងារ

សំខាន់ និងចាំបាច់មួយ គឺការត្រូវជំរុញ និងតាមដានការអនុវត្តអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ឱ្យបានគ្រប់គោលដៅដែលបានកំនត់ និងធានាឱ្យបានលើការអនុវត្តគ្រប់សកម្មភាពដែលសម្រេចក្រោម ១០០% ឱ្យបញ្ចប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងត្រីមាសទី៤ខាងមុខ ព្រមទាំងបន្តការអនុវត្តដើម្បីសម្រេចសូចនាករទាំងអស់ ដើម្បីធានាការសម្រេចបានជាសារវ័ន្ត នូវសូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ។

## ផ្នែកទី៣: ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់

ផ្នែកទី៣ ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ត្រូវបានគាំទ្រដោយគោលបំណងចំនួន ៤ និង ចង្កោមសកម្មភាពចំនួន ១៩។ គោលបំណងទាំង ៤ រួមមាន ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី, ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ រវាង កសហវ និងក្រសួង ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ន), ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ និងពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។

ផ្អែកលើគោលបំណងដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៩៣% ដែលក្នុងនោះមានគោលបំណងចំនួន១ សម្រេចបានទាបជាង ៨០% គឺគោលបំណង ៣៤។ ចំណែកឯចង្កោមសកម្មភាពទាំង ១៩ ក្នុងនោះចង្កោមសកម្មភាពចំនួន១៣ សម្រេចបានលើស ៨០%ចង្កោមសកម្មភាពចំនួន ៣ សម្រេចបានលើស ៥០% និងចង្កោមសកម្មភាពចំនួន ៣ មិនអាចវាស់វែងបាន។

### ១. ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី

គោលបំណង ៣១ នៃផ្នែកការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ មាន៣ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពសម្រេចបាន គោលបំណងនេះសម្រេចបាន ១00% ក្នុងនោះចង្កោមសកម្មភាព ៣១.២ និង ៣១.៣ សម្រេចបាន ១០០% ដោយឡែកចង្កោមសកម្មភាព ៣១.១ គឺ ពិនិត្យឡើងវិញ និងកែលម្អការអនុវត្តថវិកាតាមកម្មវិធី មិនអាចវាស់វែងបាន ដោយមូលហេតុ សកម្មភាភាគច្រើនត្រូវបានគ្រោងអនុវត្តនៅត្រីមាសទី៤ ឆ្នាំ២០១៥ ដូចជា ការវាយតម្លៃ និងផ្តល់អនុសាសន៍ដល់ក្រសួងអនុវត្តថវិកាកម្មវិធីទាំង ១០ ។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣នេះ ឃើញថាមានសូចនាករ២ សម្រេចបានតាមគោលដៅគឺ÷

១. បានដាក់បញ្ចូល ក្រសួង ស្ថាប័ន ចំនួន១៥ បន្ថែមទៀត ដើម្បីអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០១៦ និងក្រសួងស្ថាប័នមួយចំនួនទៀត បន្តបន្ទាប់រហូតគ្រប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០១៨។

២. ផ្តល់ការបណ្តុះបណ្តាលការអនុវត្តថវិកាកម្មវិធី ដល់ក្រសួងស្ថាប័នត្រៀមអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០១៦

យោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានថវិកា ទោះបីជាមានកាផ្តល់ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលជាបន្តបន្ទាប់ត្រូវផ្តល់ឱ្យដល់ក្រសួង ស្ថាប័នដែលត្រៀមអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ ២០១៦ ក៏ប៉ុន្តែ

ក្រសួងស្ថាប័នមួយចំនួន នៅមិនទាន់បានត្រៀមលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ហើយដែលទាមទារឱ្យសុំបើកវគ្គបណ្តុះបណ្តាលបន្ថែមទៀតដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត។

ជារួម អាចសន្និដ្ឋានបានថា ការអនុវត្តថវិកាកម្មវិធីនៅតែត្រូវបានពង្រឹងនិងពង្រីកជាបណ្តើរៗ គិតមកត្រឹមត្រីមាសទី៣ ឆ្នាំ២០១៥ ទោះបីជាការអនុវត្តនៅមិនទាន់មានភាពរលូន និងជួបប្រទះបញ្ហាប្រឈមមួយចំនួនក៏ដោយ។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវខិតខំបន្ថែមទៀតជាពិសេស ដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងចំពោះការអនុវត្តចំណាយថវិកានៃការអនុវត្តថវិកាកម្មវិធីចំពោះក្រសួង ស្ថាប័នដែលកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងត្រូវផ្តល់ជំនួញបច្ចេកទេស បណ្តុះបណ្តាលបន្ថែមដល់ក្រសួងស្ថាប័នដែលត្រៀមអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០១៦។

## ២. រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាង កសហវ និង ក្រសួង ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ន)

គោលបំណង ៣២ នៃការត្រៀមសម្រាប់ជំហានបន្ទាប់ ចង្កោមសកម្មភាពចំនួន ៦។ បើផ្អែកលើសកម្មភាពសម្រេចបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ គោលបំណងនេះសម្រេចបាន ៧៥% ក្នុងនោះចង្កោមសកម្មភាព ៣២.១ សម្រេចបាន ១០០%, ៣២.៣ សម្រេចបាន ១០០%, ៣២.៥ សម្រេចបាន១០០% និង ៣២.៦ សម្រេចបាន៧៥%។ ដោយឡែក ចង្កោមសកម្មភាព ៣២.២ អគ្គនាយកដ្ឋានពាក់ព័ន្ធ មិនបានរៀបចំផែនការសកម្មភាពលម្អិតសម្រាប់គាំទ្រចង្កោមសកម្មភាពនេះទេ និងចំពោះសកម្មភាពដែលគាំទ្រចង្កោមសកម្មភាព ៣២.៤ ត្រូវបានអនុវត្តនៅក្នុងចង្កោមសកម្មភាពផ្សេងទៀត ហើយ អ.គ.ហ ក៏បានសម្រេចលុបចេញពីផែនការសកម្មភាពរួមដំណាក់កាលទី៣ដែលនឹងត្រូវអនុវត្តនៅឆ្នាំ២០១៦ ផងដែរ។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី២នេះ ឃើញថាមានសូចនាករ៣ សម្រេចបានពេញលេញ គឺ÷

១. មតិប្រឹក្សាច្បាប់ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានផ្តល់ជូនតាមការស្នើសុំ

២. អង្គភាពថវិកានៃក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធីពេញលេញទាំង១០ បានពិនិត្យ និងរៀបចំរួចរាល់។

៣. ក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តអំណាចហិរញ្ញវត្ថុនៅអង្គភាពថវិការបស់ក្រសួងទាំង១០ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត។

ដោយឡែកសូចនាករ ១ នៃចង្កោមសកម្មភាព ៣២.៦ សម្រេចមិនបានពេញលេញគឺ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅ អមផ្ទាល់ក្រសួង ស្ថាប័ន មិនទាន់ត្រូវបានប្រតិភូកម្ម អំណាចបន្ថែមក្នុងការចុះទិដ្ឋាការលើលិខិតធានា ចំណាយ និង អាណត្តិបើកប្រាក់សម្រាប់មុខ ចំណាយមួយចំនួន និងក្នុងទំហំទឹកប្រាក់កំណត់។ សកម្មភាពនេះបានគ្រោងនឹងបញ្ចប់តាំងពីនៅក្នុងត្រីមាសទី២មកម្លេះ។ រីឯ សូចនាករនៃចង្កោមសកម្មភាព ៣២.២និង៣២.៤ មិនអាចធ្វើការវាស់វែងបានដោយមូលហេតុដូចបានរៀបរាប់ខាងលើ។

ដូចនេះ អាចសន្និដ្ឋានបានថាការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាង កសហវ និង ក្រសួង ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ន) មិនទាន់អនុវត្តបានពេញលេញតាមគោលដៅកំណត់សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៥ នេះ ដោយហេតុថាការរៀបចំផែនការសកម្មភាពនិងការកំណត់សូចនាករមិនទាន់មានសុក្រឹតភាពនិងសង្គតិភាពពេញលេញ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាពនិងគោលបំណង។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវអនុវត្តបន្តទៀតជាពិសេសស ការរៀបចំផែនការសកម្មភាពនិងសូចនាករ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាព ៣២.២។ ជាមួយគ្នានេះដែរ ត្រូវបញ្ចប់ការអនុវត្តសកម្មភាពដែលសម្រេចមិនបានពេញលេញគឺ ការរៀបចំធ្វើប្រតិភូកម្មអំណាចបន្ថែមដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់ក្រសួងស្ថាប័ន ដោយត្រូវដោះស្រាយបញ្ហាប្រឈម ចំពោះមុខចំណាយមួយចំនួនដែលបានសិក្សាដើម្បីធ្វើប្រតិភូកម្មអំណាចមានបញ្ហាវេទយិតភាព។

## ៣. ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ

គោលបំណង ៣៣ នៃផ្នែកទី៣នេះ មានចង្កោមសកម្មភាពចំនួន ៣។ បើផ្អែកលើសកម្មភាពដែលសម្រេចបានគោលបំណងនេះសម្រេចបាន ៩៩% ក្នុងនោះ ចង្កោមសកម្មភាព ៣៣.១ សម្រេចបាន៩៧% ៣៣.២ សម្រេចបាន ១០០% និង៣៣.៣ សម្រេចបាន ១០០%។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៥ នេះ ឃើញថាមានសូចនាករ ៣ បានសម្រេចតាមគោលដៅ រួមមាន÷

១. ឯកសារណែនាំក្នុងការប្រមូលមតិយោបល់ត្រឡប់ពីអ្នកប្រើប្រាស់ទិន្នន័យនិងស្ថិតិ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត

២. បច្ចេកទេសនិងវិធីសាស្ត្រ TOFE/GFS ត្រូវបានអនុវត្ត សម្រាប់ការធានាសង្គតិភាពជាមួយ ប្លង់គណនីថ្មី; ទិន្នន័យស្ថិតិហិរញ្ញប្បទានពីក្រៅប្រទេស ទាំងក្នុង TOFE/GFS ត្រូវបានកែលម្អឱ្យមានសង្គតិភាពជាមួយគ្នា និងទិន្នន័យចំណូល និង ចំណាយថ្នាក់ក្រោមជាតិ ត្រូវបានបញ្ចូលក្នុង TOFE/GFS។

៣. ម៉ូដែលម៉ាក្រូសេដ្ឋកិច្ច ត្រូវបានត្រួតពិនិត្យឡើងវិញ និង ម៉ូដែល Financial Programming and Policies ត្រូវបានរៀបចំ។

ដូចនេះ អាចសន្និដ្ឋានបានថាការពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ នៅតែអាចធានានិងរក្សាបាន ក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ នេះ ដោយហេតុថាសកម្មភាពគាំទ្រភាគច្រើនបានសម្រេចរួចរាល់តាមគោលដៅ និងមានសកម្មភាពតិចតួចប៉ុណ្ណោះដែលមិនទាន់សម្រេចគោលដៅ ដូចជា ការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (គោលនយោបាយពាណិជ្ជកម្មទំនិញ , វិធានដើមកំណើតទំនិញ, សហប្រត្តិបត្តិការសេដ្ឋកិច្ច) នៅមិនទាន់អាចសម្រេចបានតាមគោលដៅ ដោយសារ កិច្ចប្រជុំស្តីពីកិច្ចព្រមព្រៀងមួយចំនួន ត្រូវបានរៀបចំតែពុំបានទទួលលទ្ធផលដូចការគ្រោងទុក ដែលតម្រូវអោយមានការរៀបចំកិច្ចប្រជុំបន្តទៀត។

## ៤. ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ

គោលបំណង៣៤ នៃការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ មានចង្កោមសកម្មភាពចំនួន៧។ បើផ្តែកលើសកម្មភាពដែលសម្រេចបានក្នុងត្រីមាសទី២ ឆ្នាំ២០១៥ គោលបំណងនេះសម្រេចបាន ៨០% ក្នុងនោះចង្កោមសកម្មភាព ៣៤.១ សម្រេចបាន៨៥%, ៣៤.២ សម្រេចបាន១០០%, ៣៤.៣ សម្រេចបាន៥៣%, ៣៤.៤ សម្រេចបាន៧០%, ៣៤.៥ សម្រេចបាន៩០%, ៣៤.៦ សម្រេចបាន៨៧% និង៣៤.៧ សម្រេចបាន ៧០%។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាព សម្រាប់ត្រីមាសទី៣ នេះ ឃើញថាមាន ៤ សូចនាករសម្រេចបានតាមគោលដៅ គឺ៖

១.សេចក្តីព្រាងប្រកាសបឋមស្តីពីរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅក្រុមការងារ D & D នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានដាក់ពិភាក្សាអន្តរអគ្គនាយកដ្ឋាន

២.ឯកសារគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម និងវែងត្រូវបានរៀបចំរួចរាល់

៣.ឯកសារគោលនយោបាយស្តីពីការផ្តល់មូលនិធិមានភ្ជាប់លក្ខខ័ណ្ឌ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួច
និងសេចក្តីព្រាងវិធាននិងបទប្បញ្ញត្តិនានាដើម្បីអនុវត្តយន្តការផ្តល់មូលនិធិមានភ្ជាប់លក្ខខ័ណ្ឌត្រូវបានរៀបចំ

៤.គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យនិងកែសម្រួល ព្រមទាំងបានរៀបចំបណ្តុះបណ្តាលទៅដល់អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ

ដោយឡែកមាន ៤ សូចនាករ ដែលមិនសម្រេចតាមគោលដៅ គឺ៖

១.សេចក្តីព្រាងសៀវភៅណែនាំស្តីពីការរៀបចំនិងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដាក់ពិភាក្សាជាមួយអង្គភាពពាក់ព័ន្ធ (សម្រេចបាន៦០%) និងសេចក្តីព្រាងអនុក្រឹត្យ សម្រាប់អនុវត្តប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវបានដាក់ពិភាក្សាជាមួយក្រសួងមហាផ្ទៃ និង NCDD (សម្រេចបាន៣០%)

២.សេចក្តីព្រាងអនុក្រឹត្យ/ប្រកាស ដើម្បីអនុវត្តការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រជុំពិភាក្សាជាមួយអង្គភាពពាក់ព័ន្ធ (សម្រេចបាន៧០%)

៣.រៀបចំការបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (សម្រេចបាន៨០%)

ដូចនេះ អាចសន្និដ្ឋានបានថា ក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ត្រូវបានកំពុងបន្តពង្រឹង និងពង្រីក ស្របតាមគោលដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុដំណាក់កាលទី២ បើទោះបីជាការអនុវត្តនៅមិនទាន់មានភាពរលូន និងចង្កោមសកម្មភាពមួយចំនួនមិនសម្រេចបានតាមគោលដៅក៏ដោយ។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវខិតខំបន្ថែមទៀតជាពិសេសត្រូវបញ្ចប់សកម្មភាពចំពោះសូចនាករដែលមិនសម្រេចបានតាមគោលដៅខាងលើ។

## ផ្នែកទី៤: ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព

ផ្នែកទី៤ ត្រូវបានបង្កើតឡើង សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព តាមរយៈគោលបំណងចំនួន ២ រួមមាន ៤១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ និង ៤២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត។ គោលបំណងនីមួយៗ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពអនុវត្តចំនួន២ ទៀត។

បើផ្អែកលើការសម្រេចបាននៃគោលបំណងទាំង២ នេះ ឃើញថា ផ្នែកនេះជារួមសម្រេចបាន៦២% ដោយក្នុងនោះ គោលបំណង៤១ សម្រេចបាន៦២% និងគោលបំណង៤២ សម្រេចបាន៦១%។ ក្នុងនោះ យើងអាចសន្និដ្ឋានបានថា សកម្មភាពសម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ស្ថិតនៅក្នុងកម្រិតមួយដែលពុំទាន់មានភាពសកម្មភាពខ្លាំងក្លា និងការប្តេជ្ញាចិត្តខ្ពស់ពីបណ្តាគ្រប់អគ្គនាយកដ្ឋានទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ការបង្កើនឆន្ទៈកំណែទម្រង់ ភាពជាម្ចាស់ និងការទទួលខុសត្រូវហាក់នៅមានកម្រិតទាប និងស្ថិតនៅក្នុងក្តីបារម្ភ និងពុំទាន់ឆ្លើយតបបានជាអតិប្បរមានៅឡើយ។

### ១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ រួមមាន ៤១.១ ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រង និង ៤១.២ បង្កើនឆន្ទៈកំណែទម្រង់ភាពជាម្ចាស់ និងការទទួលខុសត្រូវ។ បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះអនុវត្តបានតែ៦២% ដោយក្នុងនោះ ចង្កោមសកម្មភាព ៤១.១ សម្រេចបាន ៧៧% និង ៤១.២ សម្រេចបានតែ ៤៨%។ ក្នុងនោះ ឃើញថា សកម្មភាពមួយចំនួនសម្រេចបានពេញលេញតាមគោលដៅដែលបានកំណត់ ពោលគឺ ក្រមសីលធមិមន្ត្រីរាជការពន្ធដារត្រូវបានដាក់ឱ្យអនុវត្តតាមរយៈលិខិតលេខ៦៩៩២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តក្រមសីលធមិមន្ត្រីពន្ធដារ និងសេចក្តីណែនាំស្តីពីវិន័យរបស់មន្ត្រីពន្ធដារត្រូវបានដាក់ឱ្យអនុវត្តតាមរយៈលិខិតលេខ៧០៧៧ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តវិន័យរបស់មន្ត្រីពន្ធដារ។ ប៉ុន្តែកត្តាដែលនាំឱ្យគោលបំណងនេះសម្រេចបាននៅទាបធៀបទៅនឹងគោលដៅ គឺដោយសារអគ្គលេខាធិការដ្ឋានពុំទាន់បោះពុម្ពផ្សាយនូវកម្រងសម្រង់បទប្បញ្ញត្តិច្បាប់ ឬគតិយុត្តចំនួន៦ ពាក់ព័ន្ធនឹងវិស័យគយ, វិស័យឧស្សាហកម្មវត្ថុ, វិស័យលទ្ធកម្មសាធារណៈ, វិស័យគណនេយ្យ, កិច្ចដំណើរការរបស់កហសវ, វិស័យមុខងារសាធារណៈ ដោយសកម្មភាពទាំងអស់នេះនឹងត្រូវលើកយកទៅអនុវត្តបន្តនៅឆ្នាំ២០១៦ វិញ។ ចំពោះអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិអត់បាន

ដាក់សកម្មភាពចំនួន១ ដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយផែនការសកម្មភាពកែទម្រង់ឱ្យបានទូលំទូលាយ និងជំរុញការអនុវត្តឱ្យបានតាមផែនការសកម្មភាពដែលបានកំណត់ បើទោះបីជាមានសកម្មភាពនៅក្នុងផែនការសកម្មភាពក៏ដោយ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី១នេះ មិនទាន់បានអនុវត្តពេញលេញគ្រប់ជ្រុងជ្រោយ សម្រាប់ត្រីមាសទី៣ នេះនៅឡើយទេ។ ម្យ៉ាងវិញទៀត អង្គភាពលើសពីពាក់កណ្ដាល មិនបានរៀបចំសកម្មភាពគាំទ្រ ដើម្បីពង្រឹងដល់ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងការបណ្ដុះឆន្ទៈកំណែទម្រង់ ធ្វើឱ្យភាពជាម្ចាស់និងការទទួលខុសត្រូវនៅមានកម្រិតទាបនៅឡើយ ដែលនេះអាចបញ្ជាក់ឱ្យឃើញថា អង្គភាពមួយចំនួនពុំទាន់ឱ្យតម្លៃខ្ពស់ ឬក៏យល់ថា ខ្លួនត្រូវធ្វើអ្វីដើម្បីគាំទ្រដល់គោលបំណងនេះ។

## ២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ រួមមាន ៤២.១. ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការបណ្តុះបណ្តាល និងរៀបចំផែនការកសាងសមត្ថភាពថ្មី និង ៤២.២. ពិនិត្យមើលឡើងវិញពីយន្តការ និងអភិក្រមនៃការផ្តល់ការលើកទឹកចិត្តរយៈពេលកន្លងមកនិងរៀបចំឱ្យមានយន្តការ និងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធមិ និងសង្គតិភាព។ ជារួម ផ្អែកលើសកម្មភាពសម្រេចបានគោលបំណងនេះសម្រេចបាន ៦១%។

បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះអនុវត្តបានតែ ៦១% ដោយក្នុងនោះ ចង្កោមសកម្មភាព ៤២.១ សម្រេចបាន ៥៤% និង៤២.២ សម្រេចបានតែ៦៨%។ កត្តាដែលនាំឱ្យគោលបំណងនេះសម្រេចបាននៅទាបធៀបទៅនឹងគោលដៅ គឺអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិអត់បានដាក់សកម្មភាពចំនួន ២ ពាក់ព័ន្ធនឹងការរៀបចំឯកសារសម្រង់ទិន្នន័យដើមគ្រា ដើម្បីវាស់ស្ទង់សមត្ថភាពមន្ត្រីក្រោយទទួលបានការបណ្តុះបណ្តាលដើម្បីធ្វើការវាយតម្លៃ និងកសាងផែនការសមត្ថភាពថ្មី និងបន្តពិនិត្យយន្តការតាមដានសមិទ្ធកម្ម និងជ្រើសរើសមន្ត្រីសម្រាប់ទទួលបានការលើកទឹកចិត្ត ដើម្បីធានាបាននូវសមធមិ និងសង្គតិភាព ព្រមទាំងបន្តពង្រឹងយន្តការលើកទឹកចិត្ត និងដាក់ទណ្ឌកម្មផ្ទៃក្នុងសម្រាប់មន្ត្រីដែលសកម្ម និងអសកម្ម។ ចំណែកឯអគ្គលេខាធិការដ្ឋាន មានសកម្មភាពចំនួន៥ ក្នុងនោះពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការអភិវឌ្ឍ (R&D) ឯកសារបណ្តុះបណ្តាលតាមវិស័យជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រៀបចំនិងសម្របសម្រួលការផ្ទេរបទពិសោធន៍អន្តរជាតិពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ និងការងារកែទម្រង់ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង-ស្ថាប័ន, ការរៀបចំនិងសម្របសម្រួលការសិក្សាស្វែងយល់ពីឧត្តមានុវត្តន៍អន្តរជាតិពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជូនថ្នាក់ដឹកនាំបច្ចេកទេសនិងមន្ត្រីរាជការ, រៀបចំ និងសម្របសម្រួលការផ្លាស់ប្តូរបទពិសោធន៍អន្តរជាតិពាក់ព័ន្ធភាជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ និងការងារកែទម្រង់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ (ថ្នាក់នាយកដ្ឋាន និងរដ្ឋលេខាធិការ), និងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ, ការគ្រប់គ្រងការផ្លាស់ប្តូរ, កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (គណនេយ្យ

សាធារណៈ, លទ្ធកម្មសាធារណៈ, សវនកម្ម, ថវិកា និងអធិការកិច្ច) ជូនដល់មន្ត្រីរាជការរបស់មន្ទីរជំនាញរាជធានី ខេត្ត និងក្រសួង-ស្ថាប័ន មិនទាន់បានអនុវត្តនៅឡើយ។ ទន្ទឹមនឹងការមិនបានអនុវត្តសកម្មភាពទាំងនេះឃើញថា អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែលម្អ និងអនុម័តកម្រងឯកសារពាក់ព័ន្ធនឹងលក្ខន្តិកៈថ្មីរបស់សមាគមសង្គហៈមិត្ត សម្រេចបាន១០០%។ ចំណែក អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មិនបានអនុវត្តសកម្មភាពចំនួន២ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលសម្រាប់អ្នករៀបចំគោលនយោបាយហិរញ្ញវត្ថុ÷ មីក្រូហិរញ្ញវត្ថុ, ហិរញ្ញប្បទានសម្រាប់ SMEs, ធានាឥណទានសម្រាប់ SMEs, និងសមាហរណកម្ម និងទីផ្សារហិរញ្ញវត្ថុ និងមិនទាន់មានវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសនៅឡើយ ដើម្បីធ្វើការវាយតម្លៃសមត្ថភាពមន្ត្រីជំនាញក្រោយការបណ្តុះបណ្តាល។ ដោយឡែក អគ្គនាយកដ្ឋានរតនាគារជាតិ ការសម្រេចបាននូវសូចនាករគន្លឹះសម្រាប់មន្ត្រីរតនាគារទាំងថ្នាក់កណ្តាល និងថ្នាក់ខេត្តយល់ដឹងច្បាស់ពីការប្រើប្រាស់កម្មវិធីគ្រប់គ្រងឯកសារ គឺមិនទាន់បានពេញលេញគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារតែវឌ្ឍនភាពសម្រេចបាន គឺមន្ត្រីរតនាគារកណ្តាលបានប្រើប្រាស់គ្រប់គ្រងឯកសារ (E-Doc) ដែលមិនបានពង្រីកដល់ថ្នាក់ខេត្តនោះទេ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី២ នេះ ក៏ស្ថិតនៅក្នុងកម្រិតមួយពុំទាន់ឆ្លើយតបបានទាំងស្រុងតាមទិសដៅដែលបានដាក់ចេញ។ មូលហេតុសំខាន់ៗចំនួន៤ ហាក់នៅមានកម្រិតនៅឡើយដូចជា (១) ការពុំទាន់ពិនិត្យមើលឡើងវិញនូវតម្រូវការនៃការបណ្តុះបណ្តាល ព្រមទាំងការប្រើប្រាស់ធនធានក្រោយពីបណ្តុះបណ្តាលរួច និង (២) ឯកសារសម្រាប់ការបណ្តុះបណ្តាលសវនករបច្ចេកវិទ្យាព័ត៌មាននៅពុំទាន់បានរៀបចំរួច។

ជារួម សម្រាប់ផ្នែកនេះ យើងអាចសន្និដ្ឋានបានថា ទោះបីជាសកម្មភាពជាច្រើនបានអនុវត្តពេញលេញក្តី និងមិនពេញលេញក្តីក៏ពិតមែន តែបើពិនិត្យឱ្យបានល្អិតល្អន់ឃើញថា ៣០% នៃសកម្មភាពដែលបានដាក់ចេញហាក់ពុំទាន់មានទម្ងន់គ្រប់គ្រាន់ សម្រាប់បម្រើឱ្យផលប្រយោជន៍ពិតនៃផ្នែកនេះនៅឡើយទេ។ ដូចនេះ គ្រប់អគ្គនាយកដ្ឋានទាំងអស់ ត្រូវការពង្រឹង និងបង្កើនសកម្មភាពជាក់លាក់និងមុតស្រួចបន្ថែមទៀត ដើម្បីធានាថា ការគាំទ្រដល់ការអនុវត្តកម្មវិធីប្រកបដោយជោគជ័យ និងចីរភាពអាចសម្រេចបានពិតប្រាកដ ជាពិសេស សម្រាប់ដំណាក់កាលទី៣ អគ្គនាយកដ្ឋាន ដែលពុំបានរៀបចំសកម្មភាពគាំទ្រត្រូវខិតខំព្យាយាមរៀបចំសកម្មភាព ដើម្បីឱ្យគ្រប់អគ្គនាយកដ្ឋានទាំងអស់ក្លាយជាកម្លាំងចលករព្រមគ្នា ដើម្បីចូលរួមលើកស្ទួយការអនុវត្តកម្មវិធីកែទម្រង់បានទៅដោយរលូន៕

## III. បញ្ហាប្រឈម

- មានភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម
- កង្វះជំនួយបច្ចេកទេស និងសមត្ថភាពរបស់មន្ត្រីជំនាញនៅមានកម្រិត
- មានការយឺតយ៉ាវក្នុងការជ្រើសរើសជំនាញការដើម្បីរៀបចំប្រព័ន្ធស្តង់ដារគណនេយ្យអន្តរជាតិ (IPSAS)

- កង្វះកិច្ចសហការក្នុងការធ្វើបច្ចុប្បន្នភាពសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ (IRRPP) ដោយធ្វើសុខដុមនីយកម្មជាមួយស្តង់ដារនីតិវិធីរួម (SOPs)
- សកម្មភាពមួយចំនួនដែលបានរៀបចំនៅក្នុងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន មិនត្រូវបានអនុវត្ត

## IV. សំណូមពរ

- ស្នើអគ្គនាយកដ្ឋាន ដែលមិនបានរៀបចំសកម្មភាពគាំទ្រគោលបំណងសំខាន់នៃ CAP2-New គួររៀបចំផែនការសកម្មភាពបញ្ចូលក្នុង CAP3
- សកម្មភាព/ សូចនាករដែលបានបញ្ចប់ និងរាយការណ៍នៅក្នុងត្រីមាសមុន មិនគួរ រាយការណ៍ជាវឌ្ឍនភាពនៅក្នុងត្រីមាសបន្ទាប់
- ស្នើរៀបចំលក្ខខណ្ឌយោងការងារ (TOR) សម្រាប់ថ្នាក់ដឹកនាំរបស់អង្គភាពថវិកានៃ កសហវ។

## V. សេចក្តីសន្និដ្ឋាន

របាយការណ៍វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៥ នៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ នេះ បានបង្ហាញថា÷

- <u>ភាពជឿទុកចិត្តបាននៃថវិកា</u> សម្រេចបាន ៧៦% នៃគោលដៅ។ ភាពជឿទុកចិត្តបាននៃថវិកានៅតែអាចធានាបាន ប៉ុន្តែនៅមិនទាន់មានស្ថិរភាពនៅឡើយ។
- <u>គណនេយ្យភាពហិរញ្ញវត្ថុ</u> សម្រេចបាន៨៣%។ គណនេយ្យភាពហិរញ្ញវត្ថុ នៅតែធានាបាន ប៉ុន្តែអាចនឹងជួបប្រទះនឹងកិច្ចប្រឈមនាពេលខាងមុខ ប្រសិនបើគោលដៅសូចនាករដែលបានកំណត់ មិនត្រូវបានអនុវត្តឱ្យបានទាន់ពេលវេលា។
- <u>ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់</u> សម្រេចបាន ៩៣%។ ផ្នែកនេះ នៅតែមានលក្ខណៈល្អប្រសើរ ប៉ុន្តែការអនុវត្តពុំទាន់បានពេញលេញតាមគោលដៅដែលចង់បាននៅឡើយ។
- <u>ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព</u> សម្រេចបាន ៦២%។ ផ្នែកនេះ នៅមិនទាន់ធានាបានក្នុងត្រីមាសទី៣ នេះនៅឡើយទេ ដោយសារអគ្គនាយកដ្ឋានមួយចំនួនមិនបានរៀបចំសកម្មភាពគាំទ្រផ្នែកនេះ។